KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 70 /2025 MFA.IC

PRESS RELEASE

**Permanent Representative of the Kingdom of Cambodia to the United Nations in New York Requests the United Nations Security Council to "demand that the Thai Armed Forces immediately cease their illegal armed aggression against the Kingdom of Cambodia".**

On 10 December 2025, His Excellency **Keo Chhea,** Permanent Representative of Kingdom of Cambodia to the United Nations in New York, submitted a letter to His Excellency **Samuel Žbogar,** Permanent Representative of the Republic of Slovenia to the United Nations, President of the United Nations Security Council (UNSC), to bring the UNSC's urgent attention and to request the latter to take a decisive action on a series of unprovoked, unjustified, unlawful, and escalating armed aggressions committed by the Thai Armed Forces against the Kingdom of Cambodia, which have started since 7 December 2025 and continued unabated.

The Permanent Representative of Cambodia informed the President of the UNSC that, "On 7 December 2025, at 14:15, Thai Armed Forces opened fire on Cambodian positions with heavy weapons, continuing until 14:32. Later that same day, from 20:02 until 20:50, they fired numerous mortar rounds aimed at multiple Cambodian locations. On 8 December 2025, beginning at 05:04, Thai forces... escalated their assault by using mortars, tanks, heavy artillery, drones, war planes, and toxic smoke against our positions in multiple areas along the border in Preah Vihear and Oddar Meanchey provinces. ...Thailand's deployment of fighter aircrafts, have been brutal and indiscriminate, and conducted in the most blatant disregard of civilian lives and in total disrespect of international humanitarian norms."

His Excellency **Keo Chhea** added that as of now, "Thai forces extended their attacks into non-combat, civilian zones within Banteay Meanchey province in violation of bilateral agreements and terms set forth in the Kuala Lumpur Peace Accord to settle the border dispute and border demarcation through peaceful means and international law and to refrain from the threat or use of force... Thai armed forces continue expanding their attacks into other non-combat, civilian zones within two other Cambodian provinces - Pusat and



Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

Battambang... resulted in numerous death and injuries, including innocent civilians, extensive destruction of their homes, public infrastructure, and protected national heritage monuments, including the Temple of Preah Vihear. Thailand's deliberate and indiscriminate targeting of civilian areas constitutes a serious breach of international humanitarian law, in particular with regards to its obligations to distinguish at all time between civilian and military targets and prohibition of attacks at civilians."

Despite these serious provocations and sustained attacks that have placed Cambodia in an increasingly precarious and dangerous situation, the Permanent Representative of Cambodia clearly reaffirmed that, "Cambodia has remained fully committed to its obligations as set forth in the Charter of the United Nations—most importantly Article 2(3) on the peaceful settlement of disputes and Article 2(4) on the prohibition of force...Cambodia does not wish to be compelled into considering means of response other than through diplomacy and dialogue to defend its people and uphold its territorial integrity... Cambodian forces have exercised maximum restraint and refrained from retaliatory response for 24 hours... However, Cambodia reserves its right to self-defense in accordance with Article 51 of the Charter of the United Nations."

In relation to the existing mechanisms and agreements to which Thailand and Cambodia are parties including the principle of *uti juris possidetis*, His Excellency **Keo Chhea** emphasized that, "Thailand's actions represent a flagrant and continuous violation of the Ceasefire Agreement of 28 July 2025 and a fundamental breach of the Kuala Lumpur Peace Accord, signed on 26 October 2025, whereby Thailand has unilaterally announced its suspension, undermining it through its offensive cross-border military operations based on unilaterally-drawn maps contrary to the mutually agreed maps at the scale of 1/200,000, which are the results of the demarcation work of the Commission of Delimitation of the Boundary between Indo-China and Siam established by the Convention of 1904 and the Treaty of 1907 between France and Siam, recognized by the International Court of Justice (ICJ) and reaffirmed by Cambodia and Thailand in the Memorandum of Understanding on the Survey and Demarcation of the Land Boundary signed on 14 June 2000 (MOU 2000)... registered at the United Nations by Thailand on 25 May 2011 and was published in the UN Treaty Series."

Having seen Thai Armed Forces continue to severely impede the enormous progress painstakingly achieved through bilateral negotiations and international facilitations; the seriousness of the situation on the ground; considered the urgent need to prevent further deterioration; pursuant to Articles 34 and 35(1) of the Charter of the

United Nations; and mindful of the Secretary-General's authority under Article 99, the Permanent Representative of Cambodia respectfully requests the UNSC to:

1. "Unequivocally condemn Thailand's unprovoked armed aggression against the Kingdom of Cambodia in violation of Article 2(4) of the Charter of the United Nations and fundamental principles of international law;"
2. "Demand an immediate cessation of all attacks by Thai Armed Forces, including artillery bombardments and fighter aircraft operations, in violation of Cambodia's sovereignty and territory;"
3. "Demand that the Thai Armed Forces immediately cease their illegal armed aggression against Cambodia, halt all attempts to invade or encroach Cambodia's sovereignty and territory through the use of unilaterally-drawn maps, and fully respect internationally recognized borders and legally binding instruments;"
4. "Demand that Thailand cease all violations of international humanitarian law, including attacks on civilian areas and civil targets, and comply fully with the principles of humanity, distinction, and proportionality; and fully respect Cambodia's sovereignty and territorial integrity;"
5. "Dispatch an independent United Nations fact-finding mission to ascertain the facts on the ground, investigate Thailand's violations of international law, and determine its responsibility for civilian casualties and material destruction."

After having urgently appealed the UNSC to take decisive action, His Excellency **Keo Chhea** reiterated that, "Cambodia remains firmly committed to peaceful dialogue, diplomacy, and adherence to international law...to fully implement the Ceasefire Agreement and the Kuala Lumpur Peace Accord... However, Cambodia cannot—and should not—be expected to endure these unrelenting and unlawful aggression indefinitely."

Phnom Penh, 11 December 2025

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**លេខ៖ បព ៧០/២០២៥ កបទ.សអ** 　　　　　　　　　　　　　　　　　　　　　　　　សេចក្តីប្រកាសព័ត៌មាន

## តំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក ស្នើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ «ទាមទារឱ្យកងកម្លាំងប្រដាប់អាវុធថៃ បញ្ឈប់ជាបន្ទាន់នូវការឈ្លានពានប្រដាប់អាវុធដោយខុសច្បាប់មកលើកម្ពុជា»

នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម កែវ ឈា** តំណាងអចិន្ត្រៃយ៍នៃព្រះរាជាណាចក្រកម្ពុជាប្រចាំអង្គការសហប្រជាជាតិ នៅទីក្រុងញូវយ៉ក បានផ្ញើលិខិតជូនឯកឧត្តម Samuel Žbogar តំណាងអចិន្ត្រៃយ៍នៃសាធារណរដ្ឋស្លូវេនីប្រចាំអង្គការសហប្រជាជាតិ និងជាប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSC) ដោយស្នើក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យយកចិត្តទុកដាក់ និងចាត់ការជាបន្ទាន់ និងម៉ឺងម៉ាត់បំផុត ចំពោះសកម្មភាពឈ្លានពានប្រដាប់អាវុធ ដោយគ្មានការញុះញង់ជាមុន គ្មានហេតុផល និងខុសច្បាប់ ដែលកំពុងបន្តប្រព្រឹត្តទៅកាន់តែខ្លាំងឡើងពីសំណាក់កម្លាំងយោធាថៃប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ចាប់តាំងពីថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ មក។

តំណាងអចិន្ត្រៃយ៍កម្ពុជាបានជម្រាបជូនប្រធាន UNSC ថា «នៅថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ១៤:១៥នាទី កងកម្លាំងយោធាថៃ បានបើកការបាញ់ប្រហារមកលើទីតាំងកម្ពុជាដោយអាវុធធុនធ្ងន់ បន្តរហូតដល់ម៉ោង ១៤:៣២។ នៅយប់ថ្ងៃដដែល ចាប់ពីម៉ោង ២០:០២នាទី ដល់ម៉ោង ២០:៥០នាទី យោធាថៃបានបាញ់កាំភ្លើងត្បាល់មកលើទីតាំងជាច្រើនកន្លែងក្នុងដែនអធិបតេយ្យរបស់កម្ពុជា។ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០២៥ ចាប់ពីវេលាម៉ោង ០៥:០៤នាទីព្រឹក យោធាថៃបានបង្កើនការវាយលុក ដោយប្រើកាំភ្លើងត្បាល់ រថក្រោះ កាំភ្លើងធុនធ្ងន់ យន្តហោះគ្មានមនុស្សបើក យន្តហោះចម្បាំង និងបាញ់ផ្សែងពុលមកលើតំបន់ជាច្រើនតាមព្រំដែនក្នុងខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។... ការវាយប្រហារដោយប្រើប្រាស់យន្តហោះចម្បាំងរបស់ប្រទេសថៃបានប្រព្រឹត្តទៅយ៉ាងឃោរឃៅ គ្មានរើសមុខ ដោយមិនខ្វល់ខ្វាយពីអាយុជីវិតប្រជាជនស៊ីវិលស្លូតត្រង់ និង គ្មានការគោរពទាល់តែសោះដល់បទដ្ឋានមនុស្សធម៌អន្តរជាតិ។»

**ឯកឧត្តម កែវ ឈា** បានបន្ថែមថា មកដល់ពេលនេះ «យោធាថៃបានពង្រីកការវាយប្រហាររបស់ខ្លួនទៅកាន់តំបន់ដែលមានប្រជាជនស៊ីវិលរស់នៅ និងមិនមែនជាទីតាំងសមរភូមិ នៅក្នុងខេត្តបន្ទាយមានជ័យ ដោយរំលោភលើកិច្ចព្រមព្រៀងទ្វេភាគី និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងគូឡាឡាំពួ ដើម្បីដោះស្រាយវិវាទព្រំដែន និងការងារខណ្ឌសីមាព្រំដែនដោយសន្តិវិធី យោងតាមច្បាប់អន្តរជាតិ ដោយចៀសវាងការគំរាមប្រើប្រាស់កម្លាំង ឬការប្រើប្រាស់កម្លាំង។... យោធាថៃ បានបន្តពង្រីកការវាយ

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh

ប្រហាររបស់ខ្លួនទៅតំបន់មិនមែនជាសមរភូមិ និងជាលំនៅដ្ឋានរបស់ប្រជាជនស៊ីវិល ក្នុងខេត្តចំនួនពីរផ្សេងទៀតរបស់កម្ពុជា គឺខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង...បណ្តាលឱ្យមានការបាត់បង់ជីវិត និងរបួសជាច្រើននាក់ រួមទាំងជនស៊ីវិលស្លូតត្រង់ ការបំផ្លិចបំផ្លាញផ្ទះសម្បែងប្រជាជន ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងប្រាង្គប្រាសាទបេតិកភណ្ឌជាតិ រួមទាំងប្រាសាទព្រះវិហារផងដែរ។ ការផ្តោតគោលដៅវាយប្រហារលើតំបន់ស៊ីវិលដោយចេតនា ដោយឥតរើសមុខ ពីសំណាក់កម្លាំងយោធាថៃ គឺជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ជាពិសេសចំពោះកាតព្វកិច្ចរបស់ខ្លួន ក្នុងការបែងចែកឱ្យច្បាស់រវាងគោលដៅស៊ីវិល និងគោលដៅយោធា ព្រមទាំងការហាមឃាត់មិនឱ្យមានការវាយប្រហារលើជនស៊ីវិល។»

តំណាងអចិន្ត្រៃយ៍កម្ពុជាបានគូសបញ្ជាក់ថា ទោះជាត្រូវរងការរំលោភបំពានដ៏ធ្ងន់ធ្ងរ និងការវាយប្រហារជាបន្តបន្ទាប់ ដែលបានធ្វើឱ្យកម្ពុជាធ្លាក់ក្នុងស្ថានភាពផុយស្រួយ និងគ្រោះថ្នាក់កាន់តែធ្ងន់ធ្ងរ «កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះកាតព្វកិច្ចរបស់ខ្លួន តាមសេចក្តីចែងនៃធម្មនុញ្ញអង្គការសហប្រជាជាតិ ក្នុងមាត្រា ២(៣) ស្តីពីការដោះស្រាយវិវាទដោយសន្តិវិធី និងមាត្រា ២(៤) ស្តីពីការហាមប្រើកម្លាំង... ។ កម្ពុជាមិនចង់ឱ្យត្រូវបង្ខំចិត្តធ្វើការឆ្លើយតបតាមវិធីណាមួយផ្សេងក្រៅពីផ្លូវការទូត និងការសន្ទនាគ្នានោះឡើយ ដើម្បីការពារជីវិតប្រជាជន និងបូរណភាពទឹកដីរបស់ខ្លួន...។ កងកម្លាំងកម្ពុជាបានអត់ធ្មត់ជាអតិបរិមា និងមិនបានធ្វើការឆ្លើយតបរយៈពេល ២៤ម៉ោង។... ទោះជាយ៉ាងនេះក្តី កម្ពុជារក្សាសិទ្ធិការពារខ្លួន ដោយផ្អែកលើមាត្រា ៥១ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ។»

ទាក់ទងនឹងយន្តការ ក៏ដូចជាកិច្ចព្រមព្រៀងមានស្រាប់ ដែលថៃ និងកម្ពុជាសុទ្ធតែជារដ្ឋភាគី រួមទាំងគោលការណ៍ច្បាប់អន្តរជាតិស្តីពីការមិនកែប្រែព្រំដែន ដែលបន្សល់ទុកពីសម័យអាណានិគម ( *uti juris possidetis* )» **ឯកឧត្តម កែវ ឈា** បានគូសបញ្ជាក់ថា «សកម្មភាពរបស់ថៃ គឺជាការរំលោភយ៉ាងពិតប្រាកដ ម្តងហើយម្តងទៀតលើកិច្ចព្រមព្រៀងឈប់បាញ់ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងគូឡាឡាំពួ ដែលចុះហត្ថលេខា នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥។ ភាគីថៃបានប្រកាសផ្អាកអនុវត្តជាឯកតោភាគី និងបានបំផ្លាញស្មារតីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងគូឡាឡាំពួ តាមរយៈការបើកប្រតិបត្តិការយោធាឆ្លងព្រំដែន ដោយផ្អែកលើផែនទីដែលគូសជាឯកតោភាគី ដែលផ្ទុយពីផែនទីមានការទទួលស្គាល់ដោយភាគីទាំងពីរ គឺផែនទីមានមាត្រដ្ឋាន ១/២០០.០០០ ដែលជាលទ្ធផលនៃការងាររបស់គណៈកម្មការចំរុះខណ្ឌសីមាព្រំដែនរវាងឥណ្ឌូចិន និងសៀម តាមអនុសញ្ញាឆ្នាំ ១៩០៤ និងសន្ធិសញ្ញាឆ្នាំ១៩០៧ រវាងបារាំង និងសៀម ដែលទទួលស្គាល់ដោយតុលាការយុត្តិធម៌អន្តរជាតិ (ICJ) និងត្រូវបានបញ្ជាក់ឡើងវិញដោយកម្ពុជា និងថៃ នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការវាស់វែង និងខណ្ឌសីមាព្រំដែនគោក ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០០០ (MOU 2000)... ។ អនុស្សរណៈនៃការយោគយល់គ្នានេះត្រូវបានភាគីថៃយកទៅចុះបញ្ជីនៅអង្គការសហប្រជាជាតិកាលពីថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១១ និងត្រូវបានផ្សព្វផ្សាយនៅក្នុងបញ្ជីសន្ធិសញ្ញារបស់អង្គការសហប្រជាជាតិ។»

ដោយមើលឃើញថា យោធាថៃនៅតែបន្តរំលោភបំពានយ៉ាងគឃ្លើនដល់វឌ្ឍនភាពដ៏ធំធេង ដែលសម្រេចបានតាមរយៈការចរចាទ្វេភាគី និងការសម្របសម្រួលពីមិត្តអន្តរជាតិ ព្រមទាំងស្ថានភាពកាន់តែធ្ងន់ធ្ងរឡើងនៅសមរភូមិជាក់ស្តែង ក៏ដូចជាការមើលឃើញពីភាពចាំបាច់ជាបន្ទាន់ក្នុងការទប់ស្កាត់កុំឱ្យ

ស្ថានការណ៍នេះកាន់តែអាក្រក់ថែមទៀត ដោយផ្អែកលើមាត្រា ៣៤ និង ៣៥(១) នៃធម្មនុញ្ញអង្គការសហប្រជាជាតិ និងដោយគោរពលើសិទ្ធិអំណាចរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ក្រោមមាត្រា ៩៩, តំណាងអចិន្ត្រៃយ៍របស់កម្ពុជាបានស្នើឱ្យក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ (UNSC) ចាត់វិធានការដូចខាងក្រោម៖

១. «ថ្កោលទោសយ៉ាងដាច់អហង្ការចំពោះការឈ្លានពានដោយកម្លាំងយោធាថៃដោយគ្មានការញុះញង់ជាមុន ប្រឆាំងនឹងព្រះរាជាណាចក្រកម្ពុជា ដែលជាការរំលោភលើមាត្រា ២(៤) នៃធម្មនុញ្ញ អង្គការសហប្រជាជាតិ និងគោលការណ៍ជាមូលដ្ឋាននៃច្បាប់អន្តរជាតិ។»

២. «ទាមទារឱ្យបញ្ឈប់ជាបន្ទាន់នូវការវាយប្រហារដោយយោធាថៃ រួមទាំងការបាញ់ផ្លោងដោយកាំភ្លើងធំ និងប្រតិបត្តិការយន្តហោះចម្បាំង ដែលរំលោភអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា។»

៣. «ទាមទារឱ្យយោធាថៃបញ្ឈប់ជាបន្ទាន់នូវការឈ្លានពានដោយខុសច្បាប់លើកម្ពុជា បញ្ឈប់ការប៉ុនប៉ងវាយលុក ឬរំលោភលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា តាមរយៈការប្រើប្រាស់ផែនទីដែលគូសដោយឯកតោភាគី ហើយត្រូវគោរពយ៉ាងពេញលេញនូវខ្សែបន្ទាត់ព្រំដែនដែលទទួលស្គាល់ដោយអន្តរជាតិ និងលិខិតូបករណ៍នានាដែលមានកាតព្វកិច្ចផ្លូវច្បាប់។»

៤. «ទាមទារឱ្យភាគីថៃបញ្ឈប់រាល់ការរំលោភច្បាប់មនុស្សធម៌អន្តរជាតិ រួមទាំងការវាយប្រហារលើតំបន់ស៊ីវិល និងគោលដៅស៊ីវិល ហើយត្រូវគោរពយ៉ាងពេញលេញនូវគោលការណ៍មនុស្សជាតិ ការញែកឱ្យដាច់ពីគ្នាលើគោលដៅវាយប្រហារ និងភាពសមាមាត្រគ្នា ព្រមទាំងគោរពយ៉ាងពេញលេញលើអធិបតេយ្យ និងបូរណភាពទឹកដីរបស់កម្ពុជា។»

៥. «បញ្ជូនបេសកកម្មស្វែងរកការពិតជាឯករាជ្យរបស់អង្គការសហប្រជាជាតិ ដើម្បីបញ្ជាក់ពីការពិតនៅទីតាំងជាក់ស្តែង ស៊ើបអង្កេតលើការរំលោភច្បាប់អន្តរជាតិពីសំណាក់ប្រទេសថៃ និងកំណត់ការទទួលខុសត្រូវរបស់ថៃ ចំពោះការស្លាប់ និងរងរបួសរបស់ជនស៊ីវិល និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ។»

បន្ទាប់ពីបានអំពាវនាវជាបន្ទាន់ដល់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឱ្យចាត់វិធានការយ៉ាងម៉ឺងម៉ាត់ **ឯកឧត្តម កែវ ឈា** បានបញ្ជាក់ជាថ្មីថា «កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងមុតមាំចំពោះការសន្ទនាដោយសន្តិវិធី វិធីសាស្ត្រការទូត និងការគោរពច្បាប់អន្តរជាតិ... និងការអនុវត្តកិច្ចព្រមព្រៀងឈប់បាញ់ និងកិច្ចព្រមព្រៀងសន្តិភាពទីក្រុងគូឡាឡាំពួឱ្យបានពេញលេញ។ ទោះជាយ៉ាងនេះក្តី កម្ពុជាមិនអាច ហើយក៏មិនគួរបន្តការអត់ធ្មត់ដោយគ្មានពេលកំណត់ឡើយ ចំពោះការឈ្លានពាន ឥតឈប់ឈរដោយខុសច្បាប់។»

ថ្ងៃព្រហស្បតិ៍ ៦រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២៥